# វត្តសំពៅប្រាំ៖ ស្ថាបត្យកម្មខ្មែរដើមសតវត្សទី២០ លើភ្នំបូកគោ

សំពៅប្រាំ ជាឈ្មោះកូនអារាមព្រះពុទ្ធសាសនាដ៏តូចច្រឡឹងមួយ កសាងឡើងក្នុងរវាងដើមសតវត្សទី២០ ដែលមានទីតាំងស្ថិតនៅលើកំពូលភ្នំបូកគោ នៃខេត្តកំពត។ វត្តដ៏ចំណាស់នេះ ជាកស្តុតាងយ៉ាងសំខាន់បង្ហាញឲ្យឃើញពីសេរីភាពនៃជំនឿក្នុងសង្គមខ្មែរដែលរួមមានទាំងព្រះពុទ្ធសាសនា គ្រិស្តសាសនា និងជំនឿលើអារក្សអ្នកតានៅទីនោះផងដែរ។ ឈ្មោះវត្តសំពៅប្រាំ ទំនងយកលំនាំតាមរឿងព្រះថោងនាងនាគ ជាព្រេងនិទានមួយដែលខ្មែរទូទៅភាគច្រើនចងចាំគ្រប់ៗគ្នាទោះបីចាំដោយអន្ទើ ឬពីដើមដល់ចប់ក្តី។ ព្រេងនិទាននេះធ្លាប់បានប្រមូលរៀបរៀង ដោយ លី ធាមតេង ហើយបានផ្តល់ជូនទៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ[1] បោះពុម្ពផ្សាយនៅឆ្នាំ១៩៧៤[2] ហើយដែលមានសេចក្តីយ៉ាងសង្ខេបដូចខាងក្រោម[3]៖

ក្នុងកាលកន្លងយូរមកហើយ មានស្តេចមួយអង្គព្រះនាមព្រះថោង។ វេលាមួយទ្រង់បានយាងចេញពីព្រះបរមរាជវាំងតាមសំពៅទៅដល់ឆ្នេរខ្សាច់ ដែលមានដើមថ្លកមួយដើមដុះនៅលើឆ្នេរខ្សាច់នោះ។ ព្រះអង្គក៏បញ្ឈប់ពលសេហ៍ឲ្យសម្រាកនៅក្រោមដើមថ្លកនោះ។ ពេលព្រឹកព្រលឹមស្វាងឡើង ព្រះថោងបានយាងក្រសាលឆ្នេរតែមួយអង្គឯងលម្ហែព្រះកាយតាមមាត់សមុទ្រឆ្ងាយទៅ។ ស្រាប់តែឮសូរសំឡេងមនុស្សអ៊ូអរ ទ្រង់ក៏យាងទៅជិតក៏ជួបនឹងនាងនាគ ដែលកំពុងនាំគីលៀងកម្សាន្តឆ្នេរ។ ព្រះថោងបានលួងលោមសុំស្នេហ៍ នាងនាគក៏ព្រមព្រៀងតែសុំឲ្យព្រះថោងតោងកន្ទុយនាគ ចូលទៅថ្វាយបង្គំព្រះបាទកុដង្គនាគជាបិតា។ លុះព្រះអង្គតាមទៅដល់ឋាននាគអស់រយៈពេលប្រាំពីរថ្ងៃ ក៏សុំលាព្រះបិតាក្មេកនាំមហេសីវិលមកឋានមនុស្សវិញ។ កាលនោះព្រះបាទកុដង្គ

---

[1] បង្កើតឡើងដោយព្រះរាជក្រឹត្យលេខ១២ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៣៤ ហើយជាគណៈកម្មការចុងក្រោយបំផុតនៃអតីតវិទ្យាស្ថានពុទ្ធសាសនាបណ្ឌិត្យ នៅរាជធានីភ្នំពេញ

[2] ឆ្នាំ២០០១ គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយរបស់ក្រសួង អ.យ.ក បានបោះពុម្ពឡើងវិញ

[3] ខ្លឹមសារមួយផ្នែកនៃរឿងនេះដូចនឹងរឿងនគរគោកធ្លោកដែរ។ សូមអានបន្ថែម៖ https://www.yosothor.org/publications/khmer-renaissance/chapter-three/NokorKokthlok.html

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

នាគ បានរៀបចំប្រដាប់ប្រដាជាទ្រព្យមានតម្លៃចំនួនប្រាំសំពៅ ដើម្បីដង្ហែព្រះរាជបុត្រមកគ្រងរាជ្យនៅឋានមនុស្សលោក។ សំពៅទាំងប្រាំ បានបើកក្តោងសំដៅដល់មាត់សមុទ្រជាយដែនប្រទេស ហើយក៏ចូលចតតម្រៀបគ្នារើប្រដាប់ប្រដា និងវត្ថុមានតម្លៃចេញពីសំពៅ ហើយដឹកជញ្ជូនយកទៅរកដីទួលខ្ពស់រៀបចំកសាងជាទីក្រុង។ ឯសំពៅទាំងប្រាំនោះក៏ចតទុកសម្រាប់ព្រះអង្គមានដំណើរទៅណាមកណា ទ្រង់គង់ក្រសាលតាមព្រះបំណង។ លុះអស់កាលជាយូរលង់មក ឆ្នេរសមុទ្រក៏ចេះតែថយឆ្ងាយទៅៗ ដីក៏កាន់តែដុះខ្ពស់ឡើងៗ សំពៅទាំងប្រាំនោះក៏កឿងជាប់នឹងឆ្នេរ ហើយយូរៗទៅក៏រឹងទៅជាថ្មលិចកប់នៅសល់តែក្តោងទាំងប្រាំដែលគេឃើញសព្វថ្ងៃនេះ។[៤]

យោងតាមឯកសារប្រវត្តិសាស្ត្រ និងចារឹកផ្ទាល់លើតួចេតិយឲ្យដឹងថា វត្តសំពៅប្រាំកសាងក្នុងឆ្នាំ១៩២៤ ក្នុងរាជ្យ ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្សព្រះខត្តិយកោដ្ឋ ប្រហាក់ប្រហែលគ្នានឹងព្រះរាជដំណាក់របស់ព្រះអង្គ ស្ថាបនាឡើងនៅផ្នែកម្ខាងទៀតនៃកំពូលភ្នំនេះ ជាទីដែលព្រះអង្គទ្រង់សោយទិវង្គតកាលពីឆ្នាំ១៩៤១។[៥] កាលពីសម័យកសាងនោះដោយទ្រង់យល់ថា បារាំងរៀបចំធ្វើទីសំណាក់អាស្រ័យល្ហែនឹងធម្មជាតិសម្រាប់ពួកគេ ដូច្នោះព្រះមហាក្សត្រទ្រង់ព្រះតម្រិះដល់ព្រះពុទ្ធសាសនា ចាត់សាងអារាមដោយមានកូនវិហារតូចមួយ និងចេតិយមួយ។ សំណង់វត្តនេះតាំងនៅលើដីខ្ពស់ជាកំពូលភ្នំដ៏មានផែនថ្មធំៗនៅពាសពេញ ចម្លែកជាងគេគឺផែនថ្មជាបន្ទះៗចំនួន៥ មានទំហំបណ្តោយប្រមាណជាង១០ ម៉ែត្រ និងកម្ពស់ប្រហែលជិតដប់ម៉ែត្រដែរ។ ទ្រង់ទ្រាយផែនថ្មនេះសំប៉ែត ហើយខ្ពស់ទ្រទុង មានសណ្ឋានដូចសំពៅ៥ កំពុងបើកក្តោង ហើយការកសាងវត្តនេះ ក៏ត្រូវធ្វើនៅជាប់ផែនថ្មទាំង៥ ទើបអ្នកផងហៅដោយសន្មតថា "វត្តសំពៅប្រាំ" ដូចរៀបរាប់មកខាងដើម។[៦]

---

[៤] ប្រជុំរឿងព្រេងខ្មែរ ភាគ៦, ១៩៧៤ : ៥៦-៥៨

[៥] នរោត្តម សីហនុ ១៩៨០: ១៨-២០

[៦] ប្រជុំរឿងព្រេងខ្មែរ ភាគ៦, ១៩៧៤: ៥៦-៥៧

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

សំណង់បុរាណចាប់ផ្តើមកសាងដំបូងក្នុងអារាមវត្តសំពៅប្រាំនេះ គឺមានតែព្រះវិហារ ចេតិយ និងសំណង់រណបមួយចំនួនតែប៉ុណ្ណោះ។ លក្ខណៈទូទៅនៃសំណង់ស្ថាបត្យកម្មដើមក្នុងបរិវេណវត្តនេះមានទំហំតូចៗ មិនធំលុបមាឌ តែប្រកបដោយក្បូនខ្នាត និងក្បូរក្បាច់រចនាយ៉ាងវិចិត្រ ជាពិសេសគួរឱ្យកត់សម្គាល់ គឺព្រះវិហារដ៏តូចទ្រនាប់ប្រកបដោយសិល្បៈ។ ព្រះវិហារមានបណ្តោយប្រហែលជាង១០ម៉ែត្រ ទទឹងប្រហែល៧ម៉ែត្រ និងមានទ្វារចេញតែមួយគត់នៅទិសខាងកើត។ តួវិហារសង់ឡើងអំពីថ្ម ដំបូល២ថ្នាក់ ប្រក់ក្បឿងស្រកាលេញលម្អដោយនាគដងក្តារតាមព្រំដំបូល និងមានហោជាងមុខក្រោយបំពាក់ដោយជហ្វាបួន តែពុំមានមណ្ឌបឡើយ។ លក្ខណៈនេះគេអាចហៅបានថា វិហារជហ្វា៤ ឬវិហារបុរាណ។[៧] តាមក្បាលសសរនីមួយៗ មានលម្អដោយកិន្នរទ្រចុងដំបូល។ ទន្ទឹមនឹងវិហារនេះមានសំណង់តូចមួយទៀត ជាប្រភេទអគារដំបូលបេតុង និងពុំមានលម្អដោយក្បូរក្បាច់អ្វីឡើយ។ សំណង់នេះ ប្រហែលដើមឡើយមានមុខនាទីជាសាលាឆាន់ ជ្បិតនៅជាប់ក្បែរៗនោះមានកូនបន្ទប់តូចៗ ដែលទំនងជាកុដ្ឋិសម្រាប់ព្រះសង្ឃគង់នៅ។ រីឯនៅផ្នែកខាងក្រោយវិហារ មានសំណង់ចេតិយធំបង្គួរមួយ ដែលមានរចនាសម្ពន្ធសំណង់ទូទៅហាក់មានលក្ខណៈស្រដៀងនឹងបូជនីយដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ ពោលគឺមានព្រះវិហារនៅខាងមុខ និងចេតិយសង់នៅខាងក្រោយ។ លក្ខណៈស្ថាបត្យកម្មបែបនេះកម្រឃើញក្នុងសម័យបច្ចុប្បន្ន ដែលភាគច្រើនកសាងចេតិយធំៗនៅមុខវិហារ។ ប៉ុន្តែក្រោយចប់សង្គ្រាម បរិវេណវត្តក៏បានពង្រីកធំជាងមុន មានសំណង់ផ្សេងៗទៀតដូចជាសាលាឆាន់ និងកុដិ ព្រះសង្ឃគង់ និងព្រះពុទ្ធបដិមាតម្កល់បូជានៅតាមទីសាធារណៈ ព្រមទាំងកន្លែងសក្ការៈជាច្រើនទៀត៕

[៧] ព្រាប ចាន់ម៉ារ៉ា ២០១៧:១៣-១៧

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## បញ្ជីរូបភាព



រូបលេខ១៖ បរិវេណ និងរចនាសម្ពន្ធសំណង់នានាស្ថិតនៅវត្តសំពៅ (ប្រាំមើលពីជ្រុងពាយ័ព្យ)



រូបលេខ២៖ ជណ្តើរឡើងទៅកាន់បរិវេណវិហារ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៣៖ ចេតិយស្ថិតនៅក្រោយព្រះវិហារ (មើលពីខាងលិច)



រូបលេខ២៤៖ ស្នាមចារឹកបញ្ជាក់ឆ្នាំកសាងចេតិយ (១៩២៤)



រូបលេខ២៥៖ ក្បាច់លម្អហោជាងខាងមុខនៃវិហារ



រូបលេខ២៦៖ ព្រះវិហារ (មើលពីជ្រុងឦសាន)



រូបលេខ២៧៖ បង្អួចឈើ រចនាលម្អនឹងក្បាច់ពុម្ព



រូបលេខ២៨៖ កិន្នរទ្រចុងដំបូល



រូបលេខ២៩៖ ដំបូលគ្រឿងស្រកាលេញ និងនាគដងក្តារលម្អដំបូល

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ឯកសារយោង

**ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ**

១៩៧៤, ប្រជុំរឿងព្រេងខ្មែរ, វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

**នរោត្តម សីហនុ**

១៩៨០ [១៩៩៣], អនុស្សាវរីយ៍ផ្អែមល្ហែម និងជូរចត់, ភ្នំពេញ

**ព្រាប ចាន់ម៉ារ៉ា,**

២០១៧, សំណង់នៅតាមវត្ត, ភ្នំពេញ

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION